Water SHED
Water, Sanitation & Hygiene Enterprise Development



# កម្មវិធីការអប់រំភាពជាអ្នកដឹកនាំ ២០១៨-២០១៩៖ ការវិភាគប្រសិទ្ធផលនៃការចំណាយ

## របាយការណ៍សង្ខេប

សហការដៃគូជាមួយ WaterAid

# មាតិកា


១.០ សេចក្តីផ្តើម៖ កម្មវិធីការអប់រំភាពជាអ្នកដឹកនាំ២០១៨-១៩ (អង្គការវ៉តែធើសេដ និង អង្គការវ៉តែធើអេដ).....៣

២.០ វិធីសាស្រ្តនៃការវិភាគ.....៤

៣.០ លទ្ធផលសំខាន់ៗនៃការវិភាគ.....៤

៤.០ សរុបសេចក្តី និង អនុសាសន៍.....៨

## ១.០ សេចក្តីផ្តើម៖ កម្មវិធីការអប់រំភាពជាអ្នកដឹកនាំ២០១៨-១៩ (អង្គការវ៉េតធើសេដ និង អង្គការវ៉េតធើអេដ)

អង្គការវ៉េតធើសេដប្រើយុទ្ធសាស្ត្របែបប្រព័ន្ធដើម្បីបង្កើត ទីផ្សារ ផលិតផល និង សេវាកម្មទឹកស្អាតនិងអនាម័យ នៅទីជនបទក្នុងប្រទេសកម្ពុជា។ នៅចន្លោះឆ្នាំ២០១៣-២០១៤ អង្គការវ៉េតធើសេដបានធ្វើ ការសាកល្បងលើ «កម្មវិធីការអប់រំភាពជាអ្នកដឹកនាំ» ដែលជាកម្មវិធីស៊ីជម្រៅមួយសម្រាប់បណ្តុះបណ្តាលសមត្ថភាពថ្នាក់ដឹកនាំមូលដ្ឋាន។ កម្មវិធីនេះមានចំណុចខុសប្លែកមួយចំនួនពីកម្មវិធី បណ្តុះបណ្តាលសមត្ថភាពដ៏ទៃទៀត។ ក្រុមប្រឹក្សាឃុំត្រូវតែដាក់ពាក្យនិងបង់ថ្លៃដើម្បីចូលរួម។ មិនតែប៉ុណ្ណោះ ជាជាងការអង្គុយចាំទទួលមេរៀនស្រាប់ៗពីវគ្គបណ្តុះ បណ្តាលតែមួយលើក អ្នកចូលរួមគឺជាអ្នកដឹកនាំដំណើរការកម្មវិធីបណ្តុះបណ្តាលដោយខ្លួនឯង និងជាច្រើនលើក ដែលមានរយៈពេល១០ខែ ។ តាមរយៈដំណើរការនៃការបង្កើតចក្ខុវិស័យអភិវឌ្ឍសហគមន៍ ការបង្កើតផែនការសកម្មភាព និង ការអនុវត្តផែនការ ដូចមានអនុវត្តក្នុងវគ្គបណ្តុះបណ្តាល កម្មវិធីនេះផ្តល់ការបណ្តុះបណ្តាលជំនាញភាពជាអ្នកដឹកនាំ ដើម្បីជម្រុញអោយមានលទ្ធផលជាក់លាក់ដែលទទួលបាននៅក្នុងវិស័យអនាម័យ។ ជាចុងក្រោយ អង្គការវ៉េតធើសេដសង្ឃឹមថា អង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត ក៏ដូចជាក្រសួងពាក់ពន្ធ័ (ដូចជាក្រសួងមហាផ្ទៃជាដើម) នឹងបន្តយកកម្មវិធីនេះទៅអនុវត្តនៅពេលខាងមុខ។

ការវាយតម្លៃទៅលើលទ្ធផលនៃវគ្គសាកល្បងកម្មវិធីការអប់រំភាពជាអ្នកដឹកនាំនេះ បានបង្ហាញថា មានការកើនឡើងជាគំហុកលើការធ្វើបង្កន់អនាម័យ នៅក្នុងស្រុកចំនួន២ ដែលបានចូលរួមកម្មវិធី បើប្រៀបធៀបទៅនឹងស្រុកដែលមិនបានចូលរួមកម្មវិធី។ យើងបានពង្រីក និងបន្តអនុវត្ត កម្មវិធីនេះបន្ថែមទៀត នៅចន្លោះឆ្នាំ២០១៥-២០១៦ ព្រមទាំងបានស្វែងរកវិធីសាស្ត្រផ្សេងៗ ដើម្បីធ្វើអោយកម្មវិធីនេះកាន់តែអាចពង្រីកវិសាលភាពនិង មានការចំណាយដោយមានប្រសិទ្ធភាពជាងមុន។

កម្មវិធីវគ្គចុងក្រោយបំផុត ត្រូវបានដាក់អោយដំណើរការក្នុងខេត្តចំនួន៧ នៅចន្លោះឆ្នាំ ២០១៨-១៩។ ការចំណាយទាំងអស់នៃវគ្គនេះ ត្រូវបានរាប់បញ្ចូលគិតចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០១៧ បន្តរហូតដល់ ខែតុលា ឆ្នាំ២០១៩។ ខេត្តនីមួយៗនិយាយជារួម បានឆ្លងកាត់សកម្មភាពវគ្គបណ្តុះបណ្តាលដែលមានរយៈពេល១០ខែ ប៉ុន្តែខេត្តទាំងនោះមិនបានចាប់ផ្តើមដំណើរការសកម្មភាពក្នុងពេលជាមួយគ្នានោះទេ។ អង្គការវ៉េតធើសេដបានកែប្រែកម្មវិធីនេះជាថ្មី ដើម្បីពង្រឹងបន្ថែម ឱ្យមន្ត្រីថ្នាក់ខេត្តដើរតួនាទីកាន់តែសំខាន់ ក្នុងការផ្តល់មូលនិធិ ក៏ដូចជាដឹកនាំអនុវត្តកម្មវិធីក្នុងវគ្គនេះ។

ការសិក្សាស្រាវជ្រាវនេះ បង្ហាញពីការវិភាគលើប្រសិទ្ធផលនៃការចំណាយ (cost-efficiency analysis, CEA) របស់កម្មវិធីការអប់រំភាពជាអ្នកដឹកនាំ ២០១៨-១៩។

ប្រសិទ្ធិផលនៃការចំណាយរបស់កម្មវិធីនេះ ត្រូវបានប្រៀបធៀបជាមួយនឹងចំណុចគោលខាងក្នុង (របស់ស្ថាប័ន) ដោយធ្វើការប្រៀបធៀបរវាងខេត្តដែលមានការអនុវត្តកម្មវិធីប្រកបដោយ ប្រសិទ្ធផលទាប ឬ ខ្ពស់ ហើយព្យាយាមរកឱ្យឃើញថាកត្តាអ្វីដែលនាំឱ្យមានកម្រិតប្រសិទ្ធិផលខុសគ្នាបែបនេះ។ បន្ទាប់មក ប្រសិទ្ធផលនៃការចំណាយរបស់កម្មវិធីនេះ ត្រូវបានប្រៀបធៀបជាមួយនឹងចំណុចគោលខាងក្រៅ (មិនមែនរបស់ស្ថាប័ន) ដោយធ្វើការប្រៀបធៀបជាមួយនឹងកម្មវិធីផ្សព្វផ្សាយអនាម័យពាក់ព័ន្ធផ្សេងទៀត នៅជនបទនៃប្រទេសកម្ពុជា។

## ២.០ វិធីសាស្ត្រនៃការវិភាគ

ការវិភាគប្រសិទ្ធផលនៃការចំណាយនេះ ត្រូវបានធ្វើឡើងដោយផ្អែកលើទស្សនៈនៃការអនុវត្តកម្មវិធីសុទ្ធសាធ ហើយធ្វើការវាយតម្លៃទៅលើចំណាយបន្ថែមទាំងអស់នៃការអនុវត្តសកម្មភាព និងលទ្ធផលដែលស្តែងចេញពីការចំណាយទាំងនោះ (ដូចជា ចំនួនបង្គន់អនាម័យដែលត្រូវបាន សាងសង់) ក្រោមរូបភាពនៃគំរូនៃការអនុវត្តកម្មវិធីការអប់រំភាពជាអ្នកដឹកនាំពីរបែបផ្សេងគ្នា (ករណី A សម្រាប់គំរូទី១ និង ករណី B សម្រាប់គំរូទី២)។ យើងក៏យកចំណាយបន្ថែមនិងលទ្ធផលដែលស្តែងចេញពីចំណាយទាំងនោះ ទៅប្រៀបធៀបផងនឹងការចំណាយរបស់កម្មវិធីផ្សេងទៀត ដែលប្រើប្រាស់វិធីសាស្ត្រ ឬ បែបផែននៃការអនុវត្ត និង ប្រើប្រាស់ហិរញ្ញវត្ថុ ផ្សេងៗទៀត (ករណី C និង D) ដើម្បីជម្រុញការសាងសង់បង្គន់អនាម័យនៅជនបទនៃប្រទេសកម្ពុជា។ តារាងទី១ ខាងក្រោម បង្ហាញអំពីលក្ខណៈទូទៅនៃគំរូនៃការអនុវត្តទាំង២របស់កម្មវិធីការអប់រំភាពជាអ្នកដឹកនាំ ២០១៨-១៩ (ករណី A និង B) និង ករណីសិក្សាពីរផ្សេងទៀត (ករណី C និង D)។

**តារាងទី១៖ ករណីនីមួយៗនៃការវិភាគប្រសិទ្ធផលនៃការចំណាយ**

| | ករណី A | ករណី B | ករណី C | ករណី D |
|---|---|---|---|---|
| **ការវិភាគប្រសិទ្ធផលនៃការចំណាយ កម្រិតខេត្ត** | អង្គការវ៉តធើសេដ + រដ្ឋាភិបាល (៦ខេត្ត រៀបចំជា៥ក្រុម) | អង្គការវ៉តធើសេដ + អង្គការវ៉តធើអេដ + រដ្ឋាភិបាល (១ខេត្ត/១ក្រុម) | | |
| **ការវិភាគការចំណាយមានប្រសិទ្ធភាព កម្រិតកម្មវិធី** | **ករណី A + ករណី B:** នៃកម្មវិធីការអប់រំភាពជាអ្នកដឹកនាំ ២០១៨-១៩(៧ខេត្ត/៦ក្រុមបញ្ចូលគ្នា អនុវត្តដោយដៃគូទាំង៣) | | កម្មវីធីផ្សព្វផ្សាយអនាម័យ | កម្មវិធីដែលផ្តល់បដិភាគជាគ្រឿង (សាងសង់បង្គន់) |

## ៣.០ លទ្ធផលសំខាន់ៗនៃការវិភាគ

ការវិភាគនេះបានរកឃើញថា កម្មវិធីការអប់រំភាពជាអ្នកដឹកនាំ ២០១៨-១៩ ជាវិធីសាស្ត្រមួយដែលមានប្រសិទ្ធផលខ្ពស់ បើធៀបទៅនឹងកម្មវិធីផ្សព្វផ្សាយបង្គន់ និង កម្មវិធីផ្តលបដិភាគ ដ៏ទៃទៀត នៅជនបទប្រទេសកម្ពុជា។ នេះគឺផ្អែកទៅលើការប្រៀបធៀបអត្រាប្រសិទ្ធផលនៃការចំណាយ (Cost Efficiency Ratios, CERs) ដែលបានត្រូវវាស់វែងដោយយកការចំណាយទាំងអស់នៃកម្មវិធី ចែកនឹងលទ្ធផលជាបរិមាណ ដែលជាគោលដៅរបស់កម្មវិធី។

នៅកម្រិតខេត្ត ការអនុវត្តកម្មវីធីនេះក្នុងខេត្តមួយចំនួន (ដូចជា ខេត្តពោធិសាត់ និង តាកែវ) ប្រសិទ្ធភាពខ្ពស់ជាង រហូតដល់២ទៅ៣ដង បើប្រៀបធៀបទៅនឹងក្រុមខេត្តដែលមានប្រសិទ្ធផលនៃការចំណាយទាបបំផុត (ដូចជា ខេត្តកំពង់ចាម និង កំពង់ឆ្នាំង)។

*ការប្រៀបធៀបចំណុចគោលខាងក្នុង - ករណី A និង B*

លទ្ធផលខាងក្រោម គឺត្រូវបានបង្ហាញជា **ដុល្លាអាមេរិច ($)** ដោយផ្អែកលើតម្លៃរូបិយប័ណ្ណក្នុងឆ្នាំ ២០១៨ ដែលរាល់**ការចំណាយទាំងអស់** ត្រូវបានបូកសរុបបញ្ចូលគ្នាតាមខេត្តនីមួយៗ រួចយកទៅចែកនឹង **ចំនួនខ្ទងផ្ទះថ្មីដែលបានសាងសង់បង្គន់ចាក់ទឹក ក្នុងខេត្តនីមួយៗទាំងនោះ** ដើម្បីគណនា**អត្រាប្រសិទ្ធផលនៃការចំណាយ**ប្រចាំខេត្ត។

(អត្រាប្រសិទ្ធផលនៃការចំណាយប្រចាំខេត្ត CERs = ការចំណាយសរុបក្នុងខេត្តនីមួយៗ / ចំនួនខ្នងផ្ទះថ្មីដែលសាងសង់បង្គន់ចាក់ទឹក ក្នុងខេត្តទាំងនោះ)

ករណី A (អង្គការវ៉តើជើសេដ + រាជរដ្ឋាភិបាល ៦ខេត្ត រៀបចំជា៥ក្រុម) មានអត្រា **CERs** ជារួម $២១,០៥ បើប្រៀបធៀប នឹងករណី B (អង្គការវ៉តើជើសេដ + អង្គការវ៉តើជើអេដ+ រដ្ឋាភិបាលខេត្តកំពង់ឆ្នាំង) ដែលមានអត្រា CERs $៣៤,០៤។ នេះមានន័យថា ករណី A គឺមានប្រសិទ្ធផលនៃការចំណាយខ្ពស់ជាងករណី B សំរាប់ការអនុវត្តកម្មវិធីនេះ ។ លទ្ធផលនេះ គឺដោយសារតែការចំណាយថេរ (ប្រាក់ខែបុគ្គលិក និង ចំណាយផ្សេងៗដូចជា ថ្លៃជួលការិយាល័យនៅខេត្ត ថ្លៃសម្ភារៈការងារ ។ល។) ក្នុងខេត្តនៃករណី A ទាបជាងក្នុងខេត្តនៃករណី B។ លទ្ធផល CERs នៃ ករណី A នេះ ក៏ចង្អុលបង្ហាញផងដែរថា កម្មវិធីការអប់រំភាពជាអ្នកដឹកនាំវគ្គនេះ គឺមានប្រសិទ្ធផលខ្ពស់ជាងកម្មវិធីវគ្គមុនៗ។ សំរាប់វគ្គសាកល្បង ២០១៣-១៤ រាល់បង្គន់សាងសង់ថ្មីនីមួយៗដែលកើតចេញពីការខិតខំប្រឹងប្រែងរបស់កម្មវិធីការអប់រំភាពជាអ្នកដឹកនាំ យើងចំណាយអស់ប្រហែល $២៦,១២ (តម្លៃដុល្លាឆ្នាំ២០១៣ ស្មើនឹង $២៨,១៤ ក្នុងឆ្នាំ២០១៨)។ រីឯវគ្គពង្រីកកម្មវិធីវិញ ២០១៥-១៦ យើងចំណាយអស់ប្រហែល $១៤.៦០ (តម្លៃដុល្លាឆ្នាំ២០១៥ ស្មើនឹង $១៥,៤៧ ក្នុងឆ្នាំ២០១៨)។ ប៉ុន្តែការចំណាយក្នុងវគ្គមុ ទាំង២នេះ មិនបានគិតបញ្ចូលការចូលរួមចំណាយរបស់ដៃគូខាងរដ្ឋាភិបាលនោះទេ មានន័យថា អត្រាCERs នៃវគ្គទាំង ២ គឺនឹងខ្ពស់ជាងតួលេខដែលបានបង្ហាញនេះ បើសិនយើងគិតទាំងការចំណាយដែលចេញពីខាងរដ្ឋាភិបាល។

**តារាងទី២៖ អត្រាCERs នៃខេត្តនីមួយៗ សម្រាប់រាល់បង្គន់សាងសង់ថ្មី (តម្លៃពេញ មិនបញ្ចុះតម្លៃ) គិតជាដុល្លាឆ្នាំ២០១៨ (កម្មវិធីការអប់រំភាពជាអ្នកដឹកនាំ ២០១៨-១៩)**

| | ករណី A | | | | | ករណី B |
|---|---|---|---|---|---|---|
| | ពោធិសាត់ | តាកែវ | ត្បូងឃ្មុំ | បាត់ដំបង/ ប៉ៃលិន | កំពង់ចាម | កំពង់ឆ្នាំង |
| ចំណាយសរុប (ចំណាយថេរ + ចំណាយប្រតិបត្តការ) | $84,278 | $64,428 | $59,789 | $82,472 | $70,094 | $117,833 |
| ចំនួនខ្នងផ្ទះដែលសាងសង់បង្គន់ចាក់ទឹកថ្មី ក្នុងអំឡុងពេល១០ខែនៃកម្មវិធី | 6,687 | 3,453 | 2,418 | 2,595 | 2,001 | 3,462 |
| CER (គិតជាដុល្លាអាមេរិច រាល់បង្គន់ថ្មីនីមួយៗ) | **$12.60** | **$18.66** | **$24.73** | **$31.78** | **$35.03** | **$34.04** |

សកម្មភាពនៃចំណុចគោលខាងក្នុងបានបង្ហាញថា កត្តាដែលធ្វើអោយខេត្តក្នុងករណី A មានការចំណាយដែលមានប្រសិទ្ធភាព មានដូចជា៖

- ការចំណាយតិចជាង សម្រាប់ខេត្តដែលធ្វើសកម្មភាព នៅទីតាំងនៅជិតអ្នកចូលរួម(ដូចជា នៅខេត្ត ពោធិសាត់) និងការចំណាយច្រើនជាង នៅពេលដែលមន្ត្រីរដ្ឋាភិបាលត្រូវធ្វើដំណើរឆ្ងាយ ដើម្បីចូលរួម។ ជាក់ស្តែង នៅក្នុងក្រុមខេត្តមួយ (បាត់ដំបង និង ប៉ៃលិន) មានមន្ត្រីរដ្ឋាភិបាលមកពីរខេត្តផ្សេងគ្នា ដែលតម្រូវឱ្យមន្ត្រីខ្លះត្រូវធ្វើដំណើរឆ្ងាយជាង ដើម្បីអាចចូលរួមក្នុងវគ្គបណ្តុះបណ្តាលបាន។
- ការចំណាយសរុបត្រូវបានរកឃើញថាមានតម្លៃខ្ពស់បំផុត នៅពេលដែលមាន ដៃគូអនុវត្តកម្មវិធីចំនួន២ ព្រមគ្នាគឺ អង្គការវ៉តើជើសេដ និង អង្គការវ៉តើជើអេដ (ខេត្តកំពង់ឆ្នាំង)។ ប៉ុន្តែ ខេត្តនេះ ក៏ត្រូវបានសង្កេតឃើញថាមានការកើនឡើងការគ្រប់ដណ្តប់អនាម័យ គួរអោយកត់សំគាល់ផងដែរ ។

- ការគណនាការចំណាយនៃសកម្មភាពការងារដែលធ្វើជាប់ៗគ្នា៖ នៅពេលដែលក្រុមការងារអង្គការវ៉េតធើរសេដ ធ្វើសកម្មភាពការងារដូចគ្នាក្នុងខេត្តច្រើន ដោយចេញដំណើរតែមួយដងពីការិយាល័យកណ្តាលនៅភ្នំពេញ ហើយមិនត្រលប់មកវិញរហូតចប់សកម្មភាពក្នុងខេត្តទាំងនោះ ការចំណាយទាំងអស់ ដែលទាក់ទងនឹងការត្រៀមរៀបចំសម្រាប់បុគ្គលិក និងការធ្វើដំណើរ ត្រូវបានដាក់បញ្ចូលជាប្រពន្ធ័ទៅក្នុងខេត្តទី១ដែលធ្វើដំណើរទៅដល់មុនគេ ក្នុងសមាមាត្រមួយដែលច្រើនជាងដាក់ទៅក្នុងខេត្តផ្សេងទៀតដែលធ្វើដំណើរទៅដល់បន្ទាប់ (ឧ. ខេត្តបាត់ដំបង/ប៉ៃលិន និង ខេត្តកំពង់ចាម)។
- ចំនួនថវិកាចំណាយសរុបនិងប្រសិទ្ធភាព៖ ខេត្តដែលមានប្រសិទ្ធភាពខ្ពស់ជាងគេ (ខេត្ត ពោធិសាត់) មិនមែនដោយសារខេត្តនេះមានការចំណាយតិចជាងគេនោះទេ ក៏ប៉ុន្តែ ជាខេត្តដែលបានត្រូវពង្រីកវិសាលភាពនៃការអនុវត្តប្រកបដោយប្រសិទ្ធភាព (ការគ្របដណ្តប់ភូមិសាស្ត្រក្នុងការអនុវត្តកម្មវិធីបានធំជាង) រួមទាំងមានការកើនឡើងបង្គន់ចាក់ទឹកក្នុងចំនួនច្រើន។
    - កត្តាមួយដែលធ្វើអោយខេត្តពោធិសាត់មានប្រសិទ្ធភាពខ្ពស់ជាងគេ រាល់បង្គន់ដែលបានសាងសង់ អាចមកពីខេត្តនេះមានចំនួនក្រុមប្រឹក្សាឃុំចូលរួមវគ្គបណ្តុះបណ្តាលការអប់រំភាពជាអ្នកដឹកនាំច្រើនជាងគេ (៥៨ នាក់) ហើយការចំណាយលើវគ្គបណ្តុះបណ្តាលវិញគឺ មានប្រសិទ្ធភាពជាងគេ (ចំណាយអស់ $ ១៤៥៣,០៧ សំរាប់ក្រុមប្រឹក្សា ឃុំម្នាក់ៗ)។
    - ស្រដៀងគ្នាដែរ ក្រុមប្រឹក្សាឃុំដែលបានចូលរួមកម្មវិធីក្នុងខេត្តពោធិសាត់នេះ មកពីបណ្តាឃុំ ដែលមានចំនួនគ្របដណ្តប់ច្រើនជាងខេត្តដ៏ទៃទៀត (៣៦ឃុំ) ដែលនេះនិយាយបានថាកម្មវិធីការអប់រំភាពជាអ្នកដឹកនាំនៅក្នុងខេត្តនេះ ត្រូវបានពង្រីកវិសាលភាពនៃការអនុវត្តដោយមាន ប្រសិទ្ធភាពខ្ពស់។

*ការប្រៀបធៀបចំនុចគោលខាងក្រៅ*

យើងយកការចំណាយ និងលទ្ធផលដែលសម្រេចបាន ក្នុងករណី A និង ករណី B បូកបញ្ចូលគ្នា ដើម្បីគណនាអត្រា CER នៅកម្រិតកម្មវិធី សម្រាប់កម្មវិធីការអប់រំភាពជាអ្នកដឹកនាំវគ្គ២០១៨-១៩នេះ។ ជារួម ការចំណាយសរុបសម្រាប់ការអនុវត្តកម្មវិធីរបស់អង្គការវ៉េតធើរសេដ អង្គការវ៉េតធើរអេដ និង ដៃគូរដ្ឋាភិបាលថ្នាក់ខេត្តនិងស្រុក មានចំនួន $៤៧៨៨៩៤ (ដុល្លាអាមេរិច ឆ្នាំ២០១៨)។ ចំនួនបង្គន់ចាក់ទឹកសរុប ដែលបានសាងសង់នៅចន្លោះពេល១០ខែនៃការអនុវត្តកម្មវិធីមានចំនួន ២០៦១៦ ដែលស្មើនឹង៦,៥% នៃកំណើនអត្រាគ្របដណ្តប់បង្គន់អនាម័យតាមខ្នងផ្ទះ នៅក្នុងចំណោមប្រជាពលរដ្ឋក្នុងឃុំទាំងអស់ដែលបានចូលរួមក្នុងកម្មវិធី។ ហើយលទ្ធផលនេះមានន័យថា អត្រា CER នៅកម្រិតកម្មវិធី គឺស្មើនឹង$២៣,២៣ ក្នុងមួយបង្គន់។ យើងយកតម្លៃ CER ធ្វើជាចំណុចគោល សម្រាប់ប្រៀបធៀបទៅនឹង តម្លៃ CER នៃកម្មវិធីផ្សព្វផ្សាយអនាម័យ និងផ្តល់បដិភាគដ៏ទៃទៀត នៅជនបទប្រទេសកម្ពុជា ដូចមានរៀបរាប់ខាងក្រោម។

ការវិភាគនេះបង្ហាញថា កម្មវិធីការអប់រំភាពជាអ្នកដឹកនាំ២០១៨-១៩នេះ គឺពិតជាមានប្រសិទ្ធភាពខ្ពស់ក្នុងការចំណាយ បើប្រៀបធៀបទៅនឹងកម្មវិធីដ៏ទៃទៀត នៅក្នុងបរិបទទីជនបទប្រទេសកម្ពុជា។

រូបភាពទី១៖ អត្រាប្រសិទ្ធផលនៃការចំណាយ (CER*) សម្រាប់កម្មវិធីផ្សព្វផ្សាយអនាម័យ និងផ្តល់បដិភាគ ក្នុងប្រទេសកម្ពុជា(គិតជាដុល្លាអាមេរិច២០១៨ សម្រាប់បង្គន់នីមួយៗ)




* មានតែ ករណី A + B ប៉ុណ្ណោះ ដែលគិតបញ្ចូលការចំណាយរបស់ រដ្ឋាភិបាលដែលជាដៃគូអនុវត្ត ដែលមានដូចជាការចំណាយទៅលើពេលវេលាធ្វើការរបស់បុគ្គលិក សម្ភារៈឧបទេសដែលមិនមែនជាសាច់ប្រាក់ និង ការចំណាយជាសាច់ប្រាក់ផ្ទាល់ខ្លួន

មានកត្តាជាច្រើនដែលរួមចំណែកធ្វើអោយកម្មវិធីការអប់រំភាពជាអ្នកដឹកនាំ២០១៨-១៩ មានប្រសិទ្ធភាពខ្ពស់ក្នុងការចំណាយ។ ជាពិសេស កម្មវិធីនេះគឺ៖

- បានផលចំណេញដោយផ្ទាល់ពី កម្មវិធីទីផ្សារអនាម័យបែបស្វ័យភាពរបស់អង្គការវ៉តធើសេដ ដែលបានធ្វើឡើងមុននេះ ហើយកម្មវិធីទីផ្សារនេះត្រូវបានរចនាឡើងតាមបែបផែននៃការវិនិយោគដើម្បីបង្កើតទីផ្សារអនាម័យក្នុងស្រុក)។
- កាត់បន្ថយចំណាយ តាមរយៈការធ្វើផែនការ និងប្រតិបត្តិការរួមគ្នាជាមួយមន្ត្រីថ្នាក់ក្រោមជាតិ។ ទាំងពេលវេលាចំណាយធ្វើការ និង ធនធានមិនមែនជាសាច់ប្រាក់របស់រដ្ឋាភិបាល ដែលបានរួមចំណែកនៅក្នុងខេត្តនីមួយៗ ដើម្បីអនុវត្តសកម្មភាពគន្លឹះទាំងអស់របស់កម្មវិធី គឺមានទំហំធំ ហើយមានប្រសិទ្ធភាពខ្ពស់ជាងខ្លាំង បើប្រៀបធៀបទៅនឹងការអនុវត្តកម្មវិធីដែលធ្វើឡើងពីការិយាល័យភ្នំពេញ ដោយបុគ្គលិករបស់អង្គការវ៉តធើសេដ ឬ ក៏អង្គការវ៉តធើអេដ។
- រដ្ឋាភិបាល និង ក្រុមប្រឹក្សាឃុំជាច្រើន នៅក្នុងតំបន់ទាំងនេះ ត្រូវបានណែនាំឱ្យស្គាល់រួចមកហើយអំពី ការផ្សព្វផ្សាយ ក៏ដូចជាទីផ្សារបង្គន់អនាម័យ តាមរយៈកម្មវិធីទីផ្សារអនាម័យបែបស្វ័យភាពរបស់អង្គការវ៉តធើសេដ ។
- កម្មវិធីនេះ ត្រូវបានធ្វើឡើងថ្មីៗនេះ ក្រោយកម្មវិធីផ្សេងៗទៀត ដែលត្រូវយកមកប្រៀបធៀបជាមួយ។ កន្លងមកជាង ១០ឆ្នាំនេះ ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចឥតដាច់ និងមានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដោយគ្មានការរំខាន ហើយថាកម្មវិធីការអប់រំភាពជាអ្នកដឹកនាំរបស់យើងគឺបានទទួលផលចំណេញពីការអភិវឌ្ឍទាំងនេះច្រើនជាង បើប្រៀបធៀបទៅនឹងកម្មវិធីដ៏ទៃទៀតដែលធ្វើពីមុន។

*ការជម្រុញការចូលរួមពីក្រុមគ្រួសារ*

រាល់ការចំណាយ១ដុល្លាអាមេរិច ដែលចំណាយទៅលើកម្មវិធីនេះដោយដៃគូធ្វើទាំងអស់ កម្មវិធីការអប់រំភាពជាអ្នកដឹកនាំនេះ អាចជំរុញអោយក្រុមគ្រួសារមួយខ្នងផ្ទះចូលរួមចំណាយ១៧,៤៧ដុល្លាអាមេរិច (ដែលនេះជាតួលេខខ្ពស់ បើប្រៀបធៀបទៅនឹងតួលេខដ៏ទៃទៀតនៅប្រទេសអាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូងផ្សេងទៀត ដែលបានអនុវត្តកម្មវិធីទីផ្សារអនាម័យផងដែរ។

*ឃុំកើនឡើងអត្រាគ្របដណ្តប់អនាម័យលើសពី៨៥%*

នៅពេលសកម្មភាព១០ខែនៃកម្មវិធីការអប់រំភាពជាអ្នកដឹកនាំនេះបានបញ្ចប់ អត្រាគ្របដណ្តប់បង្គន់អនាម័យចាក់ទឹកនៅក្នុងឃុំចំនួន១៦ ក្នុងចំណោមឃុំចំនួន ១៤៤ ដែលបានចូលរួមក្នុងកម្មវិធីនេះ បានកើនឡើងលើសពី៨៥% ដែលនេះគឺជាលក្ខខណ្ឌមួយ សំរាប់ ODF)។

កម្មវិធីការអប់រំភាពជាអ្នកដឹកនាំ២០១៨-១៩ ចំណាយ $២,៣៧ដុល្លាអាមេរិចសំរាប់មនុស្សម្នាក់ បើប្រៀបធៀបនឹងរបាយការណ៍ប្រសិទ្ធភាពនៃកម្មវិធីអនាម័យពេញលេញដឹកនាំដោយសហគមន៍ (CLTS) នៅអាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង ដែលមានការចំណាយពី ៤ ទៅ ៣៧ដុល្លាអាមេរិចសំរាប់មនុស្សម្នាក់ (គិតជាតម្លៃដុល្លាមុនឆ្នាំ២០១៥) ដោយសន្មត់ថារស់នៅក្នុងសហគមន៍ដែលមានអត្រាគ្របដណ្តប់ ODF ។ ហើយកម្មវិធីការអប់រំភាពជាអ្នកដឹកនាំ២០១៨-១៩ នេះ ក៏មានប្រសិទ្ធផលនៃការចំណាយខ្ពស់ជាង បើប្រៀបធៀបទៅនឹងកម្មវិធីCLTS មួយនៅប្រទេសកម្ពុជា ដែលផ្តល់ជំនួយដោយអង្គការមូលនិធិអនាម័យពិភពលោក ដែលមានរយៈពេលជាង៥ឆ្នាំ ដោយចំណាយអស់ ១៧ដុល្លា ក្នុងមនុស្សម្នាក់។ ចំណាំ៖ ការប្រៀបធៀបនេះមិនបានរាប់បញ្ចូល ការចំណាយរបស់ដៃគូរដ្ឋាភិបាលទេ។

## ៤.0 សរុបសេចក្តី និង អនុសាសន៍

ការសិក្សានេះបង្ហាញថា វិធីសាស្រ្តបែបប្រព័ន្ធដែលធ្វើឡើងដោយអង្គការវ៉តធើរសេដ ហើយនឹងការដាក់បញ្ចូលនៅក្នុងកម្មវិធីការអប់រំភាពជាអ្នកដឹកនាំនេះ គឺពិតជាមានប្រសិទ្ធភាពខ្ពស់។

ការសិក្សានេះបានបង្ហាញថា តាមរយៈការដាក់បញ្ចូល និងការផ្តល់អំណាចដល់ដៃគូពាក់ព័ន្ធកម្ពុជាសំខាន់ៗដែលទទួលបន្ទុកខាងវិស័យអនាម័យ (ពោលគឺ រដ្ឋាភិបាលថ្នាក់ក្រោមជាតិ និងកម្រិតមូលដ្ឋាន ក៏ដូចជាក្រុមគ្រួសារ) ដើម្បីអនុវត្តការជម្រុញវិស័យអនាម័យអោយប្រសើរឡើង កម្មវិធីនេះអាចកាត់បន្ថយការចំណាយទៅលើការអនុវត្តកម្មវិធីអភិវឌ្ឍពីខាងក្រៅ និង សម្រេចបានការចូលរួមវិភាគទានចំណាយគួរអោយកត់សម្គាល់ពីរដ្ឋាភិបាលនិងក្រុមគ្រួសារប្រជាជន។ យុទ្ធសាស្រ្តនេះគឺប្លែកពីគេ ហើយមានប្រសិទ្ធផលខ្ពស់នៃការចំណាយ។ មួយភាគធំនៃប្រសិទ្ធផលខ្ពស់នៃការចំណាយរបស់កម្មវិធីនេះ គឺកើតចេញមកពីការសហការជាមួយរដ្ឋាភិបាល ដើម្បីអនុវត្តកម្មវិធីនេះ ហើយក៏ដោយសារការវិនិយោគរបស់អង្គការវ៉តធើរសេដក្នុងការបង្កើតទីផ្សារអនាម័យជនបទពីមុនមក ដែលចូលរួមគាំទ្រដោយដៃគូអភិវឌ្ឍជាច្រើន ដែលបានឬកំពុងធ្វើការក្នុងខេត្តដូចគ្នាផងដែរ។

ការសិក្សានេះផ្តល់ជាអនុសាសន៍ថា ប្រសិនបើកម្មវិធីនេះនៅតែបន្តអនុវត្តស្រដៀងគ្នានេះដដែល កម្មវិធីនេះគួរតែត្រូវបានពិចារណា ឱ្យមានការពង្រីកវិសាលភាពទៅកាន់ខេត្តនិងស្រុកដ៏ទៃទៀត។ យ៉ាងណាមិញ យើងក៏ណែនាំអោយមានការសិក្សាបន្ថែមទៀត ដើម្បីស្វែងយល់អំពី៖ ១) ទំនាក់ទំនង និងការពឹងផ្អែករបស់វគ្គនៃកម្មវិធីនេះទៅលើវគ្គមុនៗ ឬក៏កម្មវិធីដ៏ទៃទៀត និង ២) ថាតើវាត្រឹមត្រូវកម្រិតណា ដែលយើងអាចសន្មត់យ៉ាងពិតប្រាកដថាបង្គន់ដែលបានសាងសង់ទាំងអស់ក្នុងវគ្គនេះ គឺពិតជាកើតចេញពីកម្មវិធីនេះមែន។